អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# កីឡាមួយណា?

# Which Sport Is It?



សូមស្កេនQR Code

គំនូរជីវចល    ធនធានបង្រៀន

Written by TukTuk

Illustrated by Hen Choven



« កាលពីយប់មិញ តើអ្នកបានមើលកីឡាស៊ីហ្គេមដែរឬទេ? » យ៉េកបានសួរទៅក្មេងៗ។
« ខ្ញុំបានឃើញគេលេងកីឡាមួយប្រភេទ ដែលខ្ញុំចូលចិត្ត។ ខ្ញុំដូចជាមិនចាំឈ្មោះវាជាភាសាខ្មែរទេ តែដឹងថា មានមនុស្សពីរនាក់វាយរបស់មួយទៅវិញទៅមក »។
មករានិយាយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



ថាហើយ មករាក៏បានរត់ទៅយកគ្រាប់សីមួយមក។ ក្មេងៗក៏បាននាំគ្នាទាត់វាទៅឆ្ងាយ
តាមដែលខ្លួនអាចធ្វើទៅបាន។
« មើលនែ៎! យើងអាចទាត់វាបានដល់ទៅ៣ម៉ែត្រឯណោះ! »



យ៉េកនិយាយ « មើលទៅសប្បាយណាស់ តែនេះមិនមែនជាកីឡា ដែលខ្ញុំបាននិយាយមុនហ្នឹងទេ។ គេប្រើដៃ មិនមែនប្រើជើងនោះទេ »។

រតនានិយាយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »



ពួកគេត្រឡប់មកវិញជាមួយនឹងបាល់ទះមួយគ្រាប់ ហើយចាប់ផ្តើមដក់បាល់នោះជាមួយគ្នា។
« មើលនែ៎! យើងអាចដក់បាល់ទៅវិញទៅមកបានជាង១០ដងឯណោះ! »



យ៉េកនិយាយ « មើលទៅសប្បាយណាស់ តែនេះមិនមែនជាកីឡា ដែលខ្ញុំបាននិយាយមុនហ្នឹងទេ។
គេប្រើរ៉ាកែត មិនមែនប្រើដៃនោះទេ »។
រតនានិយាយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »



នាងក៏រត់ទៅយករ៉ាកែតវាយសីម្តង។ ក្មេងៗក៏ប្រើរ៉ាកែតនោះវាយសីជាមួយគ្នា។
« មើលនែ៎! ពួកយើងអាចវាយវាទៅវិញទៅមកបានដល់ទៅ៥ដង ដោយមិនឱ្យគ្រាប់សីធ្លាក់ដល់ដីនោះទេ »។



យ៉េកនិយាយ « មើលទៅសប្បាយណាស់ តែនេះមិនមែនជាកីឡា ដែលខ្ញុំបាននិយាយមុនហ្នឹងទេ។
គេប្រើគ្រាប់តូចមួយ មិនមែនគ្រាប់សីនោះទេ »។
មករាក៏ឆ្លើយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »



ក្មេងៗក៏បានទៅយករ៉ាកែតវាយប៉េងប៉ុងនិងគ្រាប់ពណ៌ទឹកក្រូចតូចមួយមក។
« តែយើងមិនមានតុឬសំណាញ់នោះទេ » រតនានិយាយដោយទឹកមុខក្រៀមក្រំ។
មករានិយាយ « តែយើងនៅតែលេងបានអីចឹង! » ហើយមករាក៏យករ៉ាកែតវាយប៉េងប៉ុងនោះឡើងលើ។
« មើលនែ៎! ខ្ញុំអាចត្រេះគ្រាប់ប៉េងប៉ុងបានដល់ទៅមួយនាទី ដោយមិនភ្លាត់ស្នៀតឡើយ! »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



យ៉េកនិយាយ « ពិតជាល្អណាស់! តែនិយាយរួម កីឡាហ្នឹងគេលេងដោយប្រើដៃ មិនមែនប្រើជើង គេប្រើរ៉ាកែត ប្រើបាល់ មិនមែនប្រើគ្រាប់សី ហើយប្រើសំណាញ់ មិនមែនប្រើតុនោះទេ »។

រតនានិយាយ « អូ! ខ្ញុំមិនដែលឮពីកីឡាបែបនេះសោះ »។



យ៉េកនិយាយ « អូ! ខ្ញុំចាំបានហើយ! គេហៅថា កីឡាវាយកូនបាល់ »។
មកាសួរ « តើវាជាផ្នែកមួយនៃកីឡាស៊ីហ្គេមដែរឬទេ? »
« ត្រូវហើយ! វាដូចគ្នានឹងកីឡាវាយសីនិងវាយប៉េងប៉ុងអីចឹង។ ខ្ញុំស្គាល់ទីលានវាយកូនបាល់មួយកន្លែង
ហើយខ្ញុំក៏មានរ៉ាកែតនិងបាល់ផងដែរ  តើអ្នកចង់លេងទេ? » ក្មេងទាំងពីរក៏ឆ្លើយ « ចង់លេង! ចង់លេង! »



ដូច្នេះ យ៉េកក៏បានបើករ៉ឺម៉កកង់បីដឹកពួកគេទៅទីលានវាយកូនបាល់។
មករានិយាយ « ខ្ញុំវាយបាល់មិនត្រូវសោះ! ពិតជាពិបាកណាស់ »។
« មិនអីទេ »។ យ៉េកក៏បន្ត « អ្នកអាចចាប់ផ្តើមដោយបោះបាល់ឱ្យគ្នាទៅវិញទៅមក »។



ក្មេងទាំងពីរក៏បានធ្វើតាមពាក្យយ៉េកបានប្រាប់ ហើយក៏លេងបានល្អជាងមុន។
បន្តិចក្រោយមក ពួកគេអាចវាយបាល់ឆ្លងកាត់សំណាញ់ទៅវិញទៅមកបានយ៉ាងស្ទាត់ជិនាញ។



ក្រោយមក យ៉េកបានបើកទូរទស្សន៍មើលការប្រកួតកីឡាវាយកូនបាល់។ កីឡាករប្រទេសកម្ពុជាបាន
យកឈ្នះការប្រកួតនេះ ហើយពួកគេទាំងអស់គ្នាក៏បានស្រែកហូរ ជយោ...ជយោ...ជយោ...!

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



មកវានិយាយ « ខ្ញុំចង់រៀនវាយកូនបាល់បន្តទៀត។ នៅពេលដែលខ្ញុំធំឡើង ខ្ញុំប្រហែលអាចចូលរួមប្រកួតនិងយកឈ្នះគេក្នុងកីឡាស៊ីហ្គេមដែរ! »៕